អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥

# សេចក្តីថ្លែងការណ៍
## របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣

នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់លោក មាស មុត ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ដូចខាងក្រោម៖

- អំពើប្រល័យពូជសាសន៍
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភលើផ្លូវភេទ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សដោយសារស្ថានភាពនៃការឃុំខ្លួន)
- អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការធ្វើទារុណកម្ម និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
- ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ក្នុងនោះរួមមាន មនុស្សឃាតដោយចេតនា

ឧក្រិដ្ឋកម្មទាំងនេះត្រូវបានចោទថាបានប្រព្រឹត្តផ្សេងៗគ្នា៖

- នៅមន្ទីរសន្តិសុខផ្សេងៗ ក្នុងនោះរួមមាន មន្ទីរសន្តិសុខ ស-២១ (ទួលស្លែង)
- ឧក្រិដ្ឋកម្មមកលើសមាជិកកងពលលេខ ១៦៤, ៥០២, ១១៧ និង ៣១០
- នៅមន្ទីរសន្តិសុខ វត្តឥន្ទញាណ
- នៅការដ្ឋានស្ទឹងហាវ

- ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅលើកោះ និងជុំវិញកោះដែលកម្ពុជាប្រជាធិបតេយ្យ អះអាងថាជារបស់ខ្លួន
- នៅសហករណ៍តំបន់រាម រួមមាន ការដ្ឋាននៅកងកេង និងបិតត្រាំង ទីតាំងសម្លាប់មនុស្សចម្ការធូរេន និងមន្ទីរសន្តិសុខទឹកសាប។
- នៅកំពង់សោម

បទចោទមួយចំនួននៅក្នុងដីកាសម្រេចចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ដែលដាក់គាត់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ត្រូវបានលុបចោល។ ឥឡូវនេះ ដីកាសម្រេចនោះលែងមានសុពលភាព ហើយដីកាបង្គាប់ឲ្យនាំខ្លួនចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ក៏លែងមានសុពលភាពដែរ។ ដីកាបង្គាប់ឲ្យនាំខ្លួនចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ត្រូវបានលុបចោល ពីព្រោះថា លោក មាស មុត បានចូលបង្ហាញខ្លួនដោយស្ម័គ្រចិត្ត។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh